អាជ្ញាធរមីន
C.M.A.A

# ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា
# លេខ២៤

# ការស្រាវជ្រាវមូលដ្ឋាន
# (គ្រាប់បែកចង្កោម)

ខែឧសភា ឆ្នាំ២០២៤

អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
អគារថ្មីផ្លូវលេខ ២៧៣កែង៥១៦ សង្កាត់ទួលសង្កែ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: ០២៣-៨៨៥-៩៨១|០២៣-៨៨១-៨៩២
ទូរសារ: +885-23-881-308
អ៊ីមែល: info@cmaa.gov.kh
គេហទំព័រ: www.cmaa.gov.kh

# ការរក្សាសិទ្ធិ

ឯកសារនេះ គឺជាស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា (CMAS) ដែលត្រូវបានរក្សាសិទ្ធិ។ ហាមយកឯកសារនេះទាំងស្រុង ឬផ្នែកណាមួយនៃឯកសារនេះ ទៅផលិតឡើងវិញ រក្សាទុក ឬចែកចាយក្នុងទម្រង់ណាមួយ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអាជ្ញាធរមីន។

ឯកសារនេះអាចទទួលបានពីអាជ្ញាធរមីន និងមិនសម្រាប់លក់។

Contents


**អារម្ភកថា** ..... 4

**សេចក្តីផ្តើម** ..... 5

**ការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម** ..... 7

**១. វិសាលភាព និងគោលបំណងនៃស្តង់ដារនេះ** ..... 7

**២. ឯកសារយោង** ..... 7

**៣. វាក្យស័ព្ទ និងនិយមន័យ** ..... 7

**៤. គោលបំណងនៃការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម** ..... 8

**៥. លទ្ធផលនៃការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម** ..... 8

**៦. ភស្តុតាងកំណត់ចម្ការគ្រាប់បែកចង្កោមសង្ស័យ** ..... 8

**៧. ដានគ្រាប់បែកចង្កោម** ..... 9

**៨. ការគូរប្លង់ចម្ការគ្រាប់បែកចង្កោមសង្ស័យ** ..... 11

**៩. ការកំណត់ទំហំចម្ការគ្រាប់បែកចង្កោមសង្ស័យ** ..... 13

**១០. ដំណើរការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោមសង្ស័យ** ..... 13

**១១. ប្រភពព័ត៌មាន** ..... 15

**១២. លក្ខខណ្ឌតម្រូវសម្រាប់ក្រុមស្រាវជ្រាវ** ..... 16

**១៣. សុវត្ថិភាព** ..... 16

**១៤. នីតិវិធីសង្គ្រោះបន្ទាន់** ..... 17

**១៥. ការចងក្រងឯកសារ** ..... 17

**១៦. ការធានាគុណភាព (QA) និងការត្រួតពិនិត្យគុណភាព (QC)** ..... 17

**១៧. ភារកិច្ច** ..... 18

**១៨. ការទទួលខុសត្រូវ** ..... 18

១៨.១. អាជ្ញាធរមីន ..... 18

១៨.២. ប្រតិបត្តិករអនុវត្តការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម ..... 19

១៨.៣. សមាជិកសហគមន៍រងផលប៉ះពាល់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ..... 19

ឧបសម្ព័ន្ធ១៖ កំណត់ត្រាអំពីការកែលម្អ ..... 20

ឧបសម្ព័ន្ធ២៖ ស្តង់ដាចាត់ថ្នាក់ប្រភេទដី ..... 21

ឧបសម្ព័ន្ធ៣៖ ទម្រង់ទី១: ព័ត៌មានភូមិ ..... 23

ឧបសម្ព័ន្ធ៤៖ ទម្រង់ទី២ ចម្ការគ្រាប់បែកចង្កោមសង្ស័យ ..... 26

ឧបសម្ព័ន្ធ៥៖ និមិត្តសញ្ញាផែនទី ..... 33

## អារម្ភកថា

ស្តង់ដាអន្តរជាតិសម្រាប់ការបោសសម្អាតមីនមនុស្សធម៌ ត្រូវបានស្នើឡើងដោយក្រុមការងារក្នុងសន្និសីទបច្ចេកទេសអន្តរជាតិជាលើកដំបូងនៅប្រទេសដាណឺម៉ាក ក្នុងខែកក្កដា ឆ្នាំ១៩៩៦។ ជាលទ្ធផលលក្ខខណ្ឌនៃការបោសសម្អាតមីន ការបង្កើតស្តង់ដា និងនិយមន័យនៃការបោសសម្អាតមីនជាសកល ត្រូវបានពិភាក្សា និងឯកភាព។ នៅចុងឆ្នាំ១៩៩៦ ស្តង់ដាអន្តរជាតិសម្រាប់ការបោសសម្អាតមីនមនុស្សធម៌ត្រូវបានបង្កើតឡើងដោយក្រុមការងារដែលដឹកនាំដោយអង្គការសហប្រជាជាតិ ផ្អែកលើគោលការណ៍ដែលបានឯកភាពនៅប្រទេសដាណឺម៉ាក។ ស្តង់ដាអន្តរជាតិសម្រាប់ប្រតិបត្តិការបោសសម្អាតមីនមនុស្សធម៌ ត្រូវបានបោះពុម្ពជាលើកដំបូងដោយភ្នាក់ងារសេវាកម្មសកម្មភាពមីនអង្គការសហប្រជាជាតិ (UNMAS) នៅខែមីនា ឆ្នាំ១៩៩៧។

ចាប់តាំងពីពេលនោះមក វិសាលភាពនៃស្តង់ដាដើមត្រូវបានពង្រីក ដើម្បីដាក់បញ្ចូលផ្នែកផ្សេងៗនៃសកម្មភាពមីន ក្នុងគោលបំណងឆ្លើយតបទៅនឹងការវិវត្តនៃនីតិវិធីប្រតិបត្តិការ ការអនុវត្ត និងបទដ្ឋាននានា។ ស្តង់ដាអន្តរជាតិសម្រាប់ប្រតិបត្តិការបោសសម្អាតមីនមនុស្សធម៌ ត្រូវបានកែសម្រួល និងប្តូរឈ្មោះទៅជាស្តង់ដាសកម្មភាពកំចាត់មីនអន្តរជាតិ (IMAS) ដែលបានបោះពុម្ពជាលើកដំបូងនៅខែតុលា ឆ្នាំ២០០១។

អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន (អាជ្ញាធរមីន) មានតួនាទីក្នុងការបង្កើត កែសម្រួល និងថែរក្សាស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា (CMAS) ដោយផ្អែកលើស្តង់ដាសកម្មភាពកំចាត់មីនអន្តរជាតិ (IMAS) និងឧត្តមានុវត្តន៍នានា។ ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា កំណត់នូវលក្ខខណ្ឌតម្រូវអប្បបរមា និងផ្តល់នូវក្របខណ្ឌច្បាប់សម្រាប់ប្រតិបត្តិករសកម្មភាពមីនរៀបចំបទដ្ឋានប្រតិបត្តិការដើម្បីធានាបាននូវសុវត្ថិភាព ប្រសិទ្ធភាព ប្រសិទ្ធផល និងសម្រួលដល់ការអនុវត្តសកម្មភាពមីននានា។ ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជាត្រូវបានបង្កើតឡើងជាលើកដំបូងក្នុងឆ្នាំ២០០៥។

អាជ្ញាធរមីនមានភារកិច្ចបង្កើតស្តង់ដា ដោយពិគ្រោះយោបល់ជាមួយប្រតិបត្តិករសកម្មភាពមីន ដើម្បីធានាបាននូវការអនុវត្តដោយរលូន។ នៅពេលសេចក្តីព្រាងស្តង់ដាត្រូវបានរៀបចំ អាជ្ញាធរមីននឹងចែករំលែកសេចក្តីព្រាងជាមួយសមាជិកគណៈកម្មការត្រួតពិនិត្យ និងកែសម្រួលស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា (ដឹកនាំដោយអាជ្ញាធរមីន និងមានការចូលរួមពីប្រតិបត្តិករសកម្មភាពមីនដែលជាសមាជិក) ដើម្បីធ្វើការពិនិត្យ និងផ្តល់ជាគុចូល។ អាជ្ញាធរមីនមានតួនាទីក្នុងការសម្រេចចុងក្រោយលើស្តង់ដា ដែលមានថ្នាក់ដឹកនាំអាជ្ញាធរមីនជាអ្នកអនុម័តលើស្តង់ដាទាំងអស់។ ដំណើរការបង្កើត និងការកែសម្រួលស្តង់ដាត្រូវអនុវត្តតាមលំនាំខាងលើ។

## សេចក្តីផ្តើម

ប្រតិបត្តិការបោសសម្អាតមីនមនុស្សធម៌នៅកម្ពុជាបានចាប់ផ្តើមនៅឆ្នាំ១៩៩២ ដោយមានការគាំទ្រពីអាជ្ញាធរអន្តរកាលសហប្រជាជាតិនៅកម្ពុជា (UNTAC) ដើម្បីបោសសម្អាតមីនតាមផ្លូវដឹកជញ្ជូន និងសម្រួលដល់ការធ្វើមាតុភូមិនិវត្តន៍របស់ជនភៀសខ្លួនកម្ពុជារាប់សែននាក់ ដែលរស់នៅក្នុងជំរុំក្នុងប្រទេសថៃ។ ក្រោយការបោសសម្អាតមីនតាមផ្លូវត្រូវបានបញ្ចប់ ប្រតិបត្តិការបោសសម្អាតមីនបានផ្លាស់ប្តូរទៅជាការបោសសម្អាតដីដើម្បីគាំទ្រដល់ការតាំងទីលំនៅរបស់ជនមាតុភូមិនិវត្តន៍។ ដោយសារទំហំនៃការគំរាមកំហែង និងផលប៉ះពាល់នៃគ្រាប់មីន ការបោសសម្អាតត្រូវបានពង្រីកទៅដល់ការបោសសម្អាតដីកសិកម្ម គម្រោងសាងសង់ និងការអភិវឌ្ឍនានាក្នុងតំបន់។

នៅឆ្នាំ២០០០ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC) បានស្នើសុំឱ្យរដ្ឋាភិបាលប្រទេសកាណាដាផ្តល់មូលនិធិដល់ការស្រាវជ្រាវថ្នាក់ជាតិកម្រិត ១ ដើម្បីកំណត់ និងស្វែងយល់ពីតំបន់គំរាមកំហែងដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមនៅកម្ពុជា និងគាំទ្រដល់ការធ្វើផែនការ និងចាត់អាទិភាព។ រដ្ឋាភិបាលនៃប្រទេសកាណាដា តាមរយៈទីភ្នាក់ងារអភិវឌ្ឍអន្តរជាតិកាណាដា (CIDA) បានយល់ព្រមគាំទ្រ និងចុះកិច្ចសន្យាជាមួយក្រុមហ៊ុនកាណាដា GeoSpatial International ដើម្បីធ្វើការស្រាវជ្រាវថ្នាក់ជាតិកម្រិត ១ ដោយមានអង្គភាព CMAC ចូលរួម និងធនធានមនុស្ស។ គម្រោងស្រាវជ្រាវនេះចាប់ផ្តើមពីខែតុលា ឆ្នាំ២០០០ ហើយបញ្ចប់នៅខែមេសា ឆ្នាំ២០០២។ លទ្ធផលនៃការស្រាវជ្រាវបានបង្ហាញថា ៤៦% នៃចំនួនភូមិនៅទូទាំងប្រទេសកម្ពុជាដែលមានផ្ទៃដីសរុប ស្មើ ៤.៥៤៤ គីឡូម៉ែត្រការ៉េ (ប្រហែល ២,៥% នៃទឹកដីកម្ពុជា) មានការគំរាមកំហែងដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម។ លទ្ធផលដែលបានមកពីការស្រាវជ្រាវត្រូវបានផ្សព្វផ្សាយជូនរាជរដ្ឋាភិបាលតាមរយៈអង្គភាព CMAC សម្រាប់ប្រើប្រាស់ក្នុងវិស័យសកម្មភាពមីន។

ក្នុងឆ្នាំ២០០៨ អាជ្ញាធរមីនបានស្នើឱ្យប្រតិបត្តិករសកម្មភាពមីនធ្វើការគណនាទំហំផ្ទៃដីមានការគំរាមកំហែងដែលនៅសេសសល់ ក្នុងគោលបំណងរៀបចំសំណើសុំការពន្យាពេលលើកទីមួយ សម្រាប់បញ្ចប់ការបោសសម្អាតមីននៅកម្ពុជាពីឆ្នាំ២០១០-២០១៩ តាមមាត្រា៥ នៃអនុសញ្ញាស្តីពីការហាមឃាត់ ការប្រើប្រាស់ ការស្តុកទុក ការផលិត និងការផ្ទេរមីនប្រឆាំងមនុស្ស និងការបំផ្លាញចោល (ហៅកាត់ថាអនុសញ្ញាអូតាវ៉ា)។ ពេលនោះប្រតិបត្តិករសកម្មភាពមីនទាំងអស់បានទទួលស្គាល់ថា ទិន្នន័យដែលបានពីការស្រាវជ្រាវថ្នាក់ជាតិកម្រិត ១ មិនមានភាពត្រឹមត្រូវ និងមិនអាចយកជាការបាន។ ការទទួលស្គាល់នេះ ផ្អែកលើការរកឃើញមួយចំនួនដូចជាៈ ចម្ការមីនខ្លះត្រូវបានទន្រ្ទានប្រើប្រាស់ តំបន់សង្ស័យខ្លះពុំអាចកំណត់បានដោយខ្វះព័ត៌មាន និងចម្ការមីនខ្លះមានទំហំធំហួសដែលមិនអាចទទួលយកបាន។ ជាលទ្ធផល យើងរួមគ្នាឯកភាពថា ត្រូវអនុវត្តការស្រាវជ្រាវមូលដ្ឋាន ហើយលទ្ធផលពីការស្រាវជ្រាវនេះនឹងត្រូវជំនួសទិន្នន័យដែលបានពីការស្រាវជ្រាវថ្នាក់ជាតិកម្រិត ១ ។

គោលបំណងនៃការស្រាវជ្រាវមូលដ្ឋាន គឺដើម្បីកំណត់នូវទំហំតំបន់សង្ស័យមានមីនដែលនៅសេសសល់ ដោយកំណត់ព្រំប្រទល់តំបន់សង្ស័យ និងចាត់ថ្នាក់តំបន់សង្ស័យទាំងនោះទៅតាមស្តង់ដាមួយដែលបានកំណត់។ នៅពេលនោះយើងបានឯកភាពគ្នាថា ការស្រាវជ្រាវមូលដ្ឋានត្រូវអនុវត្តដោយប្រតិបត្តិករ ដែលមានបទពិសោធន៍

ក្នុងនោះមាន៖ CMAC HALO Trust MAG និងគ្រប់គ្រងដោយអាជ្ញាធរមីន ក្រោមស្តង់ដាការស្រាវជ្រាវមូលដ្ឋានចម្ការមីន ដែលនឹងត្រូវបានបង្កើតឡើងរួមគ្នាដោយអាជ្ញាធរមីន និងប្រតិបត្តិករទាំងបី។

បន្ទាប់ពីបានបង្កើតស្តង់ដា និងបទដ្ឋានប្រតិបត្តិការស្តីពីការស្រាវជ្រាវមូលដ្ឋានចម្ការមីនរួចមក ការបណ្តុះបណ្តាល ការសាកល្បងនៅទីវាល និងការចែករំលែកបទពិសោធន៍ដោយប្រតិបត្តិករទាំងបី ការអនុវត្តការស្រាវជ្រាវមូលដ្ឋានចម្ការមីនចាប់ផ្តើមឡើងនៅក្នុងខែសីហា ឆ្នាំ២០០៩ ដោយប្រតិបត្តិករទាំងបីផ្តោតលើស្រុកគោលដៅចំនួន ២៣ នៅភាគពាយ័ព្យប្រទេសតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ដែលយើងសង្ស័យថាមានមីនច្រើនបំផុត។ នៅក្នុងខែឧសភា ឆ្នាំ២០១១ ការស្រាវជ្រាវមូលដ្ឋានចម្ការមីនលើស្រុកទាំង ២៣ ត្រូវបានបញ្ចប់ ហើយការស្រាវជ្រាវនេះត្រូវបានពង្រីកទៅស្រុកដទៃផ្សេងទៀត។ នៅចុងឆ្នាំ២០១២ ស្រុកសរុបចំនួន ១២៤ ត្រូវបានបញ្ចប់ការស្រាវជ្រាវ។ ការស្រាវជ្រាវចម្ការមីនមូលដ្ឋាននៅទូទាំងប្រទេស ត្រូវបានបញ្ចប់នៅចុងឆ្នាំ២០២០ ដោយបញ្ចប់ទាំងការស្រាវជ្រាវនៅខេត្តភាគខាងកើត ដែលភាគច្រើនទទួលរងផលប៉ះពាល់ដោយសារសំណល់ជាតិផ្ទុះពីសង្គ្រាម រួមទាំងគ្រាប់បែកចង្កោមផងដែរ។

ការស្រាវជ្រាវមូលដ្ឋានត្រូវបានផ្តួចផ្តើមនៅក្នុងឆ្នាំ២០០៩ ហើយបានបញ្ចប់នៅឆ្នាំ២០២០ ប៉ុន្តែតំបន់មានការគំរាមកំហែងមួយចំនួនមិនបានស្រាវជ្រាវ និងកត់ត្រាទុកក្នុងអំឡុងពេលនោះ ដោយសារបញ្ហានៃការចាត់អាទិភាព និងតំបន់ខ្លះមិនអាចចូលបាន។ ចាប់ពីឆ្នាំ២០២០ តំបន់មានការគំរាមកំហែងត្រូវបានរាយការណ៍បន្ថែម ដូច្នេះសកម្មភាពស្រាវជ្រាវមូលដ្ឋានលើតំបន់មីន និងតំបន់មានយុទ្ធភណ្ឌគ្រឿងផ្ទុះផ្សេងទៀតរួមទាំងគ្រាប់បែកចង្កោមត្រូវតែបន្តអនុវត្ត។

ប្រតិបត្តិករដែលអនុវត្តការស្រាវជ្រាវមូលដ្ឋានលើតំបន់មានគ្រាប់បែកចង្កោម ត្រូវអនុលោមតាមស្តង់ដាលេខ ២៤ ដោយឡែកប្រតិបត្តិករស្រាវជ្រាវតំបន់មានការគំរាមកំហែងដោយសារមីន ត្រូវអនុលោមតាមស្តង់ដាលេខ ១៤ ។

គ្រាប់បែកចង្កោមដែលរកឃើញក្នុងប្រទេសកម្ពុជា មិនមានកម្រិតគំរាមកំហែងខ្ពស់ដូចគ្រាប់មីនដែលអាចផ្ទុះក្រោមសម្ពាធបង្កដោយមនុស្ស សត្វ ឬយានយន្ត។ ទោះជាយ៉ាងនេះក្តី គ្រាប់បែកចង្កោមអាចបង្កគ្រោះថ្នាក់ប្រសិនបើមានការដុត ឬប៉ះទង្គិចណាមួយ (កាប់ ជំ គប់ ឬបោក)។ ប្រសិនបើផ្ទុះ គ្រាប់បែកចង្កោមបង្កគ្រោះថ្នាក់ខ្លាំងជាងគ្រាប់មីនទៅទៀត។ គ្រាប់បែកចង្កោមមានទំហំតូច ងាយមើលឃើញ នៅលើដី និងរើសឡើង យកមកលេង ជាពិសេសចំពោះក្មេងៗ។

គ្រាប់បែកចង្កោមនៅកម្ពុជាមានកម្រិតគំរាមកំហែងទាប ដូច្នេះប្រតិបត្តិករអាចធ្វើការពង្រាយកម្លាំងក្នុងចម្ការគ្រាប់បែកចង្កោម ដោយពុំទាមទារការប្រុងប្រយ័ត្នខ្ពស់ដូចការពង្រាយកម្លាំងក្នុងចម្ការមីន។ ជាធម្មតានៅក្នុងចម្ការគ្រាប់បែកចង្កោម មិនមានការរឹតបន្តឹងលើសកម្មភាពបំលាស់ទីរបស់បុគ្គលិកនៅក្នុងពេលស្រាវជ្រាវបច្ចេកទេស លើកលែងពេលជីកកាយ ឬកម្ទេចគ្រាប់។ កត្តានេះធ្វើឱ្យការពង្រាយកម្លាំង និងការស្រាវជ្រាវមានល្បឿនលឿន ជាងការពង្រាយកម្លាំងនៅក្នុងចម្ការមីន។

## ការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម

### ១. វិសាលភាព និងគោលបំណងនៃស្តង់ដារនេះ

ស្តង់ដារនេះផ្តល់នូវគោលការណ៍ណែនាំសម្រាប់ការស្រាវជ្រាវមូលដ្ឋានក្នុងប្រទេសកម្ពុជា ដែលផ្តោតលើតំបន់ដែលមានការគំរាមកំហែងគ្រាប់បែកចង្កោមតែប៉ុណ្ណោះ និងផ្តល់លទ្ធភាពដល់ប្រតិបត្តិករដែលអនុវត្តការស្រាវជ្រាវមូលដ្ឋាន ដើម្បីរៀបចំបទដ្ឋានប្រតិបត្តិការ។

### ២. ឯកសារយោង

ស្តង់ដារយោងទាំងនេះ ជាឯកសារសំខាន់ដែលត្រូវបានប្រើប្រាស់សម្រាប់រៀបចំផ្នែកណាមួយ ឬខ្លឹមសារទាំងមូលនៃស្តង់ដារនេះ មានដូចជា៖

- ស្តង់ដារលេខ ១៤ ការស្រាវជ្រាវមូលដ្ឋាន (ចម្ការមីន)
- ស្តង់ដារលេខ ១៥ ការកាត់បន្ថយផ្ទៃដី
- ស្តង់ដារលេខ ១៥.១ ការស្រាវជ្រាវមិនបច្ចេកទេស
- ស្តង់ដារលេខ ១៥.២ ការស្រាវជ្រាវបច្ចេកទេស
- ស្តង់ដារលេខ ១៦ ការស្រាវជ្រាវសំណល់គ្រាប់បែកចង្កោម
- ស្តង់ដារលេខ ២២ ការបញ្ជ្រាបយេនឌ័រ និងភាពចម្រុះក្នុងវិស័យសកម្មភាពមីន
- ការណែនាំបន្ថែមបច្ចេកទេស (Technical Note) ០៧.១១/០៣ កិច្ចខិតខំប្រឹងប្រែងគ្រប់មធ្យោបាយសមស្រប
- ការណែនាំបន្ថែមបច្ចេកទេស (Technical Note) ០៨.២០/០២ ការស្រាវជ្រាវសំណល់គ្រាប់បែកចង្កោម។

គួរអានស្តង់ដារនេះជាមួយស្តង់ដារយោងខាងលើ ដើម្បីស្វែងយល់ឱ្យបានពេញលេញអំពីនីតិវិធីស្រាវជ្រាវ និងការបោសសម្អាតតំបន់មានការគំរាមកំហែងដោយគ្រាប់បែកចង្កោមនៅកម្ពុជា។

### ៣. វាក្យស័ព្ទ និងនិយមន័យ

- "**ការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម**" សំដៅលើសកម្មភាពស្រាវជ្រាវដែលអនុវត្តដោយប្រតិបត្តិករមានអាជ្ញាប័ណ្ណ ដើម្បីប្រមូល និងវិភាគព័ត៌មានពីសហគមន៍ក្នុងការកំណត់ទំហំ និងចាត់ថ្នាក់ប្រភេទដីនៃចម្ការគ្រាប់បែកចង្កោមសង្ស័យ ដូចមានចែងក្នុងឧបសម្ព័ន្ធ ២ ស្តីពីស្តង់ដារចាត់ថ្នាក់ប្រភេទដី។
- "**កិច្ចខិតខំប្រឹងប្រែងគ្រប់មធ្យោបាយសមស្រប**" (All Reasonable Efforts - ARE) នៅក្នុងបរិបទនៃស្តង់ដារនេះ សំដៅលើកិច្ចខិតខំប្រឹងប្រែងគ្រប់មធ្យោបាយសមស្រប និងអាចទទួលយកបាន ដើម្បីកំណត់អត្តសញ្ញាណ និងកត់ត្រាចម្ការគ្រាប់បែកចង្កោមសង្ស័យ។ ARE ត្រូវបានអនុវត្តនៅពេលលទ្ធផលរំពឹងទុកផ្តល់ផលទាបជាងធនធានដែលត្រូវចំណាយ។ ARE សម្រេចបាននៅពេលដែលគ្រប់លក្ខខណ្ឌចាំបាច់នៃស្តង់ដារនេះត្រូវបានបំពេញ។
- "**អ្នកផ្តល់ព័ត៌មានសំខាន់ៗ**" សំដៅលើបុរស ស្ត្រី និងកុមារដែលមានព័ត៌មានច្បាស់លាស់អំពីតំបន់សង្ស័យដែលមានគ្រាប់បែកចង្កោមនៅក្នុង និងជុំវិញសហគមន៍របស់ពួកគាត់។ កត់សម្គាល់៖ អ្នកផ្តល់

ព័ត៌មានសំខាន់ៗអាចជាអ្នកប្រើប្រាស់ដី ប្រធានភូមិ អ្នកដឹកនាំសហគមន៍ ជនរងគ្រោះ គ្រូបង្រៀន អ្នកដឹកនាំសាសនាជាដើម។ល។

- **"តំបន់គំរាមកំហែង"** (ដូចគ្នាទៅនឹងតំបន់មានគ្រាប់បែកចង្កោម) នៅក្នុងបរិបទនៃសកម្មភាពមីននៅកម្ពុជា ពាក្យនេះសំដៅលើតំបន់ដែលយល់ឃើញថាមានគ្រាប់បែកចង្កោម។
- **"ចម្ការគ្រាប់បែកចង្កោមសង្ស័យ"** (SHA) នៅក្នុងបរិបទនៃស្តង់ដានេះ សំដៅលើតំបន់សង្ស័យដែលមានការគំរាមកំហែងគ្រាប់បែកចង្កោមដែលបានកត់ត្រា ដោយផ្អែកលើភស្តុតាងផ្ទាល់ ឬប្រយោលតាមរយៈការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម។ កត់សម្គាល់៖ ចម្ការគ្រាប់បែកចង្កោមសង្ស័យដែលត្រូវបានធ្វើការស្រាវជ្រាវបច្ចេកទេស អាចឱ្យយើងកំណត់បាននូវចម្ការគ្រាប់បែកចង្កោមពិត (CHA)។
- ពាក្យ **"ត្រូវតែ"** ត្រូវបានប្រើដើម្បីបញ្ជាក់ពីតម្រូវការចាំបាច់ វិធីសាស្រ្ត ឬភាពជាក់លាក់ដែលត្រូវអនុវត្តឱ្យស្របទៅនឹងស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា។
- ពាក្យ **"គួរតែ"** ត្រូវបានប្រើដើម្បីបញ្ជាក់ពីតម្រូវការ វិធីសាស្រ្ត ឬភាពជាក់លាក់ផ្សេងៗទៀតដែលបានស្នើឡើង។
- ពាក្យ **"អាច"** ត្រូវបានប្រើដើម្បីបញ្ជាក់ពីវិធី ឬមធ្យោបាយដែលអាចទទួលយកបាន។

## ៤. គោលបំណងនៃការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម

គោលបំណងនៃការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម គឺប្រមូល និងវិភាគព័ត៌មានក្នុងបំណងកំណត់ និងរាយការណ៍ពីទីតាំង និងទំហំចម្ការគ្រាប់បែកចង្កោមសង្ស័យផ្អែកលើភស្តុតាងផ្ទាល់ ឬប្រយោល។

## ៥. លទ្ធផលនៃការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម

លទ្ធផលនៃការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម គឺជាចម្ការគ្រាប់បែកចង្កោមសង្ស័យ ដែលបានកំណត់ និងរាយការណ៍អំពីទីតាំង និងទំហំនៅក្នុងរបាយការណ៍ស្រាវជ្រាវទិន្នន័យមូលដ្ឋានអំពីគ្រាប់បែកចង្កោម (ឧបសម្ព័ន្ធ៤ ទម្រង់របាយការណ៍ទី២)។ ទិន្នន័យការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម ត្រូវរក្សាទុកនៅក្នុងប្រព័ន្ធទិន្នន័យសកម្មភាពមីនថ្នាក់ជាតិ រហូតដល់ចម្ការគ្រាប់បែកចង្កោមសង្ស័យទាំងនោះត្រូវបានរំដោះ។

## ៦. ភស្តុតាងកំណត់ចម្ការគ្រាប់បែកចង្កោមសង្ស័យ

គុណភាពនៃការស្រាវជ្រាវអាស្រ័យលើពីរចំណុច រួមមាន៖ ទី១ គុណភាពនៃព័ត៌មាន និងទី២ សមត្ថភាពរបស់ក្រុមស្រាវជ្រាវក្នុងការបញ្ជាក់គុណភាព និងវិភាគព័ត៌មាន រួមទាំងភស្តុតាងឱ្យបានត្រឹមត្រូវ។

### ៦.១. ភស្តុតាងផ្ទាល់សម្រាប់កំណត់ជាចម្ការគ្រាប់បែកចង្កោមសង្ស័យ

ក្នុងអំឡុងពេលស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោមជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ យ៉ាងហោចណាស់ត្រូវមានភស្តុតាងផ្ទាល់ចំនួនមួយ ដើម្បីកំណត់ជាចម្ការគ្រាប់បែកចង្កោមសង្ស័យ។ ភស្តុតាងផ្ទាល់មានដូចខាងក្រោម៖

- គ្រាប់បែកចង្កោមដែលប្រទះឃើញ
- បំណែកគ្រាប់បែកចង្កោមដែលប្រទះឃើញ
- ទីតាំងគ្រោះថ្នាក់ ឬឧប្បត្តិហេតុដោយសារគ្រាប់បែកចង្កោម ដែលគ្រាប់នោះស្ថិតក្នុងទីតាំងដើម

- ទីតាំងគ្រាប់បែកចង្កោមដែលឆ្លើយតបដោយក្រុមកម្ទេចគ្រឿងផ្ទុះ ដែលគ្រាប់នោះស្ថិតក្នុងទីតាំងដើម។

## ៦.២. ភស្តុតាងប្រយោលសម្រាប់កំណត់ជាចម្ការគ្រាប់បែកចង្កោមសង្ស័យ

ខុសពីករណីដែលមានភស្តុតាងផ្ទាល់ ក្នុងករណីនេះចាំបាច់ត្រូវមានភស្តុតាងប្រយោលយ៉ាងហោចណាស់ចំនួនពីរ ដើម្បីកំណត់ចម្ការគ្រាប់បែកចង្កោមសង្ស័យ។ ភស្តុតាងប្រយោលកាន់តែច្រើនកាន់តែធ្វើឱ្យប្រធានក្រុមមានទំនុកចិត្តកាន់តែខ្ពស់ ថាតំបន់នោះជាតំបន់មានការគំរាមកំហែង។ ក្រុមស្រាវជ្រាវត្រូវយល់ថា ភស្តុតាងប្រយោលនីមួយៗមានទម្ងន់ និងសុពលភាពខុសៗគ្នា។ ខាងក្រោមនេះគឺជាភស្តុតាងប្រយោលដែលត្រូវប្រើប្រាស់៖

- យ៉ាងហោចណាស់មានសាក្សីចំនួនពីរនាក់ ដែលបានប្រទះឃើញមួយ ឬច្រើននៃភស្តុតាងទាំងនេះ ដូចជា គ្រាប់បែកចង្កោម អំបែង បំណែកនៃគ្រាប់ តួមេគ្រាប់ ឬរណ្ដៅគ្រាប់
- គ្រាប់ផ្ទុះដោយសារភ្លើងឆេះ ឬដោយសត្វ
- ដីមិនបានប្រើប្រាស់ដោយសហគមន៍ យល់ថាមានការគំរាមកំហែងដោយសារគ្រាប់បែកចង្កោម
- ការរាយការណ៍ផ្ទាល់មាត់ពីសហគមន៍ អតីតយុទ្ធជន និងភាគីពាក់ព័ន្ធ
- ទីតាំងគ្រាប់បែកចង្កោម (ការឆ្លើយតបកម្ទេចគ្រឿងផ្ទុះ) ដែលទីតាំងគ្រាប់នោះមិនអាចបញ្ជាក់ថា ជាទីតាំងដើម
- ទីតាំងគ្រោះថ្នាក់ ឬឧប្បត្តិហេតុដោយសារគ្រាប់បែកចង្កោម ដែលទីតាំងដើមនៃគ្រាប់នោះមិនអាចបញ្ជាក់បាន។

កត់សម្គាល់៖ ក្នុងករណីដែលក្រុមស្រាវជ្រាវជួបប្រទះការលំបាកក្នុងការកំណត់ភស្តុតាងផ្ទាល់ នៅពេលដែលសហគមន៍មូលដ្ឋាននៅមានការព្រួយបារម្ភ និងជឿជាក់ថាមានការគំរាមកំហែងពីគ្រាប់បែកចង្កោម នោះក្រុមស្រាវជ្រាវត្រូវ ស្នើសុំអន្តរាគមន៍ពីក្រុមត្រួតពិនិត្យអាជ្ញាធរមីន ចុះពិនិត្យដល់ទីតាំងផ្ទាល់ ដើម្បីសម្រេចថាគួរកត់ត្រាជាចម្ការ គ្រាប់បែកចង្កោមសង្ស័យដែរឬទេ។

## ៧. ដានគ្រាប់បែកចង្កោម

កូនគ្រាប់បែកចង្កោម គឺគ្រាប់ដែលបំបែកចេញពីមេគ្រាប់បែកចង្កោម តាមរយៈការទម្លាក់ ឬការបាញ់ផ្លោង។ កូនគ្រាប់បែកចង្កោម ត្រូវបានគេរចនាឡើងសម្រាប់បំផ្ទុះមុនពេល អំឡុងពេល និងក្រោយពេលប៉ះទង្គិច។ ទិសដៅនិងទំហំនៃដានគ្រាប់បែកចង្កោម អាស្រ័យទៅលើកត្តាច្រើនដូចជាកម្ពស់ និងល្បឿនរបស់មេគ្រាប់។



រូបភាពទី ១ - ទម្រង់នៃការទម្លាក់គ្រាប់បែកចង្កោមពីលើយន្តហោះដែលកូនគ្រាប់បែកចេញពីមេគ្រាប់

ការទម្លាក់គ្រាប់បែកចង្កោម ជាធម្មតាបង្កើតជាដានគ្រាប់ ដែលមានរាងស្រដៀងនឹងពងក្រពើ។ ទោះជាគ្រាប់នោះផ្ទុះក្តី ឬមិនផ្ទុះក្តី ដានគ្រាប់អាចសម្គាល់បានតាមរយៈការរកឃើញគ្រាប់បែកចង្កោមដែលមិនទាន់ផ្ទុះ ឬកស្តុតាងគ្រាប់ដែលបានផ្ទុះហើយ។




រូបភាពទី ២ - ទម្រង់ដានគ្រាប់បែកចង្កោមដែលទម្លាក់មួយដង




រូបភាពទី ៣ - ទម្រង់ដានគ្រាប់បែកចង្កោមដែលទម្លាក់ច្រើនដង

## ៨. ការគូរប្លង់ចម្ការគ្រាប់បែកចង្កោមសង្ស័យ

ក្រុមស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោមត្រូវបង្កើតព្រំប្រទល់តំបន់សង្ស័យ ដោយផ្អែកលើភស្តុតាងផ្ទាល់ និងភស្តុតាងប្រយោល។

ការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោមលើតំបន់មានការគំរាមកំហែង ត្រូវបានកត់ត្រា/វាស់វែងដោយៈ

- ចំណុចយោង GPS Datum: WGS 1984 Universal Transverse Mercator (UTM) Zone 48N ចម្ងាយគិតជាម៉ែត្រ
- ផ្ទៃដីគិតជាម៉ែត្រការ៉េ
- ទិសគិតជាដឺក្រេ
- បញ្ជីរាយនាមភូមិសាស្ត្រ (រចនាសម្ព័ន្ធរដ្ឋបាល-ភូមិ ឃុំ ស្រុក ខេត្ត) ។

នៅពេលគូរផែនទីចម្ការគ្រាប់បែកចង្កោមសង្ស័យ ជំហានដំបូងត្រូវជ្រើសរើសយកចំណុចយោងទី១ (LM) និងចំណុចយោងទី២ (BM) ។

ចំណុចយោងទី១ (LM) គឺជាចំណុចថេរសម្រាប់ប៉ាន់ប្រមាណចម្ងាយណាមួយនៅក្រៅចម្ការគ្រាប់បែកចង្កោមសង្ស័យ។ វាគួរតែជាចំណុចថេរមួយ ដែលអាចងាយស្រួលសម្គាល់ (ដូចជាៈ ផ្លូវឆ្លងកាត់ ស្ពាន ឬអគារ ...។ល។) ដែលវាអាចជួយដល់ការនាំផ្លូវទៅកាន់ចំណុចយោងទី២ (BM) ឬចំណុចយោងច្រើនទៀត។ ចំណុចយោងទី១ នេះ គួរដាក់ផ្លាកសញ្ញាឱ្យបានរឹងមាំជាអចិន្ត្រៃយ៍។ ចំណុចយោងនេះ ត្រូវបញ្ចូលនូវព័ត៌មានជាអប្បបរមា ដូចជាៈ

- ការពិពណ៌នា
- ចំណុចយោង - កូអរដោណេ GPS
- ទិស និងចម្ងាយទៅកាន់ចំណុចយោងទី២។

ចំណុចយោងទី២ (BM) គឺជាចំណុចថេរមួយសម្រាប់បង្ហាញផ្លូវទៅចម្ការគ្រាប់បែកចង្កោមសង្ស័យ។ ជាទូទៅវាស្ថិតនៅខាងក្រៅ និងមិនឆ្ងាយពីចម្ការគ្រាប់បែកចង្កោម។ ចំណុចយោងទី២ ត្រូវងាយមើលឃើញក្នុងចម្ងាយសមរម្យ។ មិនគួរមានចំណុចយោងទី២ ប្រសិនបើចម្ការគ្រាប់បែកចង្កោមនៅក្បែរចំណុចយោងទី១។ ចំណុចយោងទី២ ត្រូវបញ្ចូលព័ត៌មានជាអប្បបរមាដូចជា៖

- ការពិពណ៌នា
- ចំណុចយោង - កូអរដោណេ GPS
- ទិស និងចម្ងាយទៅកាន់ចំណុចចាប់ផ្តើម (SP) ។

ចំណុចចាប់ផ្តើម (SP) ជាចំណុចយោងថេរ ដែលប្រើដើម្បីកំណត់ទីតាំងចាប់ផ្តើមនៃចម្ការគ្រាប់បែកចង្កោមសង្ស័យ។ ចម្ការគ្រាប់បែកចង្កោមសង្ស័យមួយ ត្រូវមានចំណុចចាប់ផ្តើម SP តែមួយប៉ុណ្ណោះ។

ចំណុចរបត់ (TP) ជាចំណុចថេរនៅលើដី ដែលបង្ហាញពីការផ្លាស់ប្តូរទិសដៅនៃព្រំប្រទល់ចម្ការគ្រាប់បែកចង្កោមសង្ស័យ ហើយវាត្រូវដាក់សញ្ញា និងកត់ត្រាឱ្យបានច្បាស់។

បន្ទាប់ពីបានកំណត់ចំណុចយោងទី១ (LM) និងចំណុចយោងទី២ (BM) ជំហានបន្ទាប់គឺត្រូវគូសផែនទីព្រំប្រទល់ចម្ការគ្រាប់បែកចង្កោមសង្ស័យ ដោយប្រើចំណុចចាប់ផ្តើម (SP) និងចំណុចរបត់ (TP)។ ចំណុចរបត់ត្រូវបង់លេខតាមលំដាប់លំដោយ (ឧទាហរណ៍៖ TP1 TP2 TP3 ...។ល។) ហើយត្រូវកត់ត្រាតាមទិសទ្រនិចនាឡិកា ដោយប្រើទិស និងចម្ងាយពីចំណុចរបត់មួយទៅចំណុចរបត់មួយទៀត។

SP/TP ដែលអាចដើរចូលបានដោយសុវត្ថិភាព ត្រូវកត់ត្រាដោយប្រើ GPS ។ ក្នុងឧទាហរណ៍នេះ ចម្ការគ្រាប់បែកចង្កោមត្រូវបានហ៊ុំព័ទ្ធដោយដីជាំដុះ ដូច្នេះ TP ទាំងអស់ត្រូវកត់ត្រាដោយប្រើ GPS ។



## ៩. ការកំណត់ទំហំចម្ការគ្រាប់បែកចង្កោមសង្ស័យ

ចម្ការគ្រាប់បែកចង្កោមសង្ស័យមួយ មិនត្រូវមានទំហំលើសពី ៣០០.០០០ ម៉ែត្រការ៉េឡើយ។ ប្រសិនបើលើសពីទំហំដែលបានកំណត់ ត្រូវបំបែកទៅជាចម្ការគ្រាប់តូចៗ។ ឧទាហរណ៍៖ តំបន់ព្រៃដែលមានផ្លូវទឹកហូរកាត់ ឬផ្លូវឆ្លងកាត់ ក្រុមស្រាវជ្រាវគួរបែងចែកចម្ការគ្រាប់បែកចង្កោមនោះជាផ្នែកដូចបានបញ្ជាក់អំពីទំហំកំណត់ ដោយផ្អែកលើព័ត៌មាន និងលក្ខណៈភូមិសាស្ត្រជាក់ស្តែង។

មិនត្រឹមត្រូវ　　　　ត្រឹមត្រូវ




ការដាក់លេខកូដចម្ការគ្រាប់បែកចង្កោមសង្ស័យ

ចម្ការគ្រាប់បែកចង្កោមសង្ស័យដែលកំណត់ដោយក្រុមស្រាវជ្រាវ ត្រូវមានលេខកូដមួយសម្រាប់សម្គាល់ ដែលមានទម្រង់ CM/CMAA/... ។ នៅពេលលេខកូដត្រូវបានដាក់ហើយ លេខនោះនឹងមិនអនុញ្ញាតិឱ្យផ្លាស់ប្តូរឡើយ ហើយលេខកូដនោះត្រូវប្រើជាលេខសម្គាល់ចម្ការគ្រាប់បែកចង្កោមសង្ស័យនោះ។

## ១០. ដំណើរការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោមសង្ស័យ

ប្រតិបត្តិករគួរធ្វើការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោមជាប្រព័ន្ធ ដោយចាប់ផ្តើមអនុវត្តវិធីសាស្ត្រពីភូមិមួយទៅភូមិមួយ និងពីឃុំមួយទៅឃុំមួយទៀត។ នៅពេលដែលការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោមត្រូវបានបញ្ចប់នៅក្នុងភូមិមួយ ក្រុមស្រាវជ្រាវនឹងទៅភូមិបន្ទាប់នៅក្នុងឃុំដដែល។ នៅពេលដែលការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម ត្រូវបានបញ្ចប់នៅក្នុងឃុំទាំងមូល ក្រុមស្រាវជ្រាវនឹងទៅភូមិមួយក្នុងឃុំថ្មី ហើយដំណើរការនេះកើតឡើងបន្តបន្ទាប់។

ដើម្បីធានាថាការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោមអនុវត្តបានគ្រប់ជ្រុងជ្រោយ ពេលទៅដល់ភូមិ និងពេលបញ្ចប់ការស្រាវជ្រាវ ក្រុមការងារស្រាវជ្រាវត្រូវពិគ្រោះជាមួយមេភូមិ និងអ្នកផ្តល់ព័ត៌មានសំខាន់ៗ។ បន្ទាប់មក មេភូមិគួរតែចុះហត្ថលេខាថាពួកគាត់ពេញចិត្ត ដែលតំបន់សង្ស័យទាំងអស់នៅក្នុងភូមិត្រូវបានក្រុមស្រាវជ្រាវ

ចុះពិនិត្យ។ ប្រសិនបើតំបន់ណាមួយនៃភូមិមិនត្រូវបានស្រាវជ្រាវដោយហេតុផលដូចជា មិនអាចរកបានអ្នកផ្តល់ព័ត៌មាន ឬបញ្ហាផ្លូវចូល ក្រុមការងារស្រាវជ្រាវត្រូវកត់ត្រាព័ត៌មាននោះក្នុងរបាយការណ៍ភូមិ (សូមមើលឧបសម្ព័ន្ធ៣ ទម្រង់របាយការណ៍ទី១) ។ នៅពេលមានឱកាសសមស្រប ក្រុមស្រាវជ្រាវដដែលគួរចុះស្រាវជ្រាវបន្តក្នុងភូមិនោះ ដើម្បីបញ្ចប់ការស្រាវជ្រាវ។

ដំណាក់កាលសំខាន់ៗក្នុងដំណើរការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម ៖

- **ជំហានទី១** (ការសិក្សាទិន្នន័យ)៖ មុនពេលក្រុមស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោមចុះស្រាវជ្រាវក្នុងតំបន់ណាមួយ ក្រុមនោះត្រូវប្រមូល ពិនិត្យ និងវិភាគព័ត៌មានដែលមានស្រាប់ (របាយការណ៍ស្រាវជ្រាវមុនៗ របាយការណ៍បញ្ចប់ការបោសសម្អាត របាយការណ៍កម្ទេចគ្រឿងផ្ទុះ របាយការណ៍ជនរងគ្រោះ ទិន្នន័យទម្លាក់គ្រាប់របស់សហរដ្ឋអាមេរិក ...។ល។) ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់នូវស្ថានភាពគ្រាប់បែកចង្កោមក្នុងភូមិ។

- **ជំហានទី២** (ការប្រជុំដើម្បីកំណត់ចម្ការគ្រាប់បែកចង្កោមសង្ស័យ)៖ បន្ទាប់ពីបានពិនិត្យ និងវិភាគព័ត៌មានដែលមានស្រាប់រួចមក ក្រុមស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោមត្រូវជួបប្រជុំជាមួយមេភូមិ និងអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដើម្បីកំណត់ទីតាំងចម្ការគ្រាប់បែកចង្កោម និងកំណត់អ្នកផ្តល់ព័ត៌មានសម្រាប់ចម្ការគ្រាប់បែកចង្កោមនីមួយៗ។

- **ជំហានទី៣** (ការចុះពិនិត្យតំបន់សង្ស័យ)៖ បន្ទាប់ពីកិច្ចប្រជុំភូមិ ក្រុមស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម រួមជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ ចុះពិនិត្យជាក់ស្តែងដល់ទីតាំងចម្ការគ្រាប់បែកចង្កោមនីមួយៗ និងសាកសួរអ្នកផ្តល់ព័ត៌មានបន្ថែម ដើម្បីប្រមូល និងវិភាគព័ត៌មានមុននឹងធ្វើការសម្រេចថាតើត្រូវកំណត់តំបន់នោះជាតំបន់សង្ស័យ (ផ្អែកលើភស្តុតាងផ្ទាល់ និងប្រយោល) ។ ប្រសិនបើព័ត៌មានដែលប្រមូលបានពុំមានភស្តុតាងអាចបញ្ជាក់ថា តំបន់នោះជាចម្ការគ្រាប់បែកចង្កោមសង្ស័យ ក្រុមស្រាវជ្រាវគួរប្រាប់ទៅអ្នកផ្តល់ព័ត៌មានវិញ ហើយបន្តចុះពិនិត្យតំបន់មួយទៀត។ ប្រសិនបើព័ត៌មានបញ្ជាក់ថា តំបន់នោះជាចម្ការគ្រាប់បែកចង្កោមសង្ស័យ ក្រុមស្រាវជ្រាវត្រូវព្យាយាមកំណត់ព្រំប្រទល់ចម្ការគ្រាប់បែកចង្កោមសង្ស័យ ហើយបន្តចុះពិនិត្យតំបន់មួយទៀត។

កត់សម្គាល់៖ ប្រសិនបើដឹងថាទីតាំងមានការគំរាមកំហែងពីគ្រាប់មីន ត្រូវបញ្ឈប់ការស្រាវជ្រាវ ហើយត្រូវ អនុវត្តតាមចំណុចលេខ ១៣ ក្នុងស្តង់ដានេះ ស្តីពីសុវត្ថិភាព។

- **ជំហានទី៤** (របាយការណ៍បញ្ចប់ការស្រាវជ្រាវ)៖ បន្ទាប់ពីបានចុះពិនិត្យគ្រប់តំបន់ដែលរាយការណ៍ថាមានការសង្ស័យមានគ្រាប់បែកចង្កោម ក្រុមស្រាវជ្រាវត្រូវរៀបចំប្រជុំ ដើម្បីរាយការណ៍ទៅមេភូមិ និងអ្នកផ្តល់ព័ត៌មានសំខាន់ៗអំពីលទ្ធផលនៃការស្រាវជ្រាវដូចជា៖ ចំនួនចម្ការគ្រាប់បែកចង្កោមសង្ស័យ ទ្រង់ទ្រាយ និងទំហំចម្ការគ្រាប់បែកចង្កោមនីមួយៗ...។ល។ មុនពេលបញ្ចប់កិច្ចប្រជុំ ក្រុមស្រាវជ្រាវត្រូវស្នើសុំឱ្យមេភូមិចុះហត្ថលេខាលើរបាយការណ៍ស្រាវជ្រាវទម្រង់ទី១ (ឧបសម្ព័ន្ធ៣) ដើម្បីបញ្ជាក់ថាគាត់បានទទួលស្គាល់លទ្ធផលនៃការស្រាវជ្រាវក្នុងភូមិ។

- **ដំហានទី៥** (ការប្រគល់លទ្ធផលស្រាវជ្រាវ)៖ បន្ទាប់ពីកិច្ចប្រជុំរាយការណ៍ ក្រុមស្រាវជ្រាវត្រូវប្រគល់ឯកសាររបាយការណ៍ទម្រង់ទី១ និងផែនទីចម្ការគ្រាប់បែកចង្កោមក្នុងភូមិចំនួន ១ច្បាប់ ជូនទៅមេភូមិដើម្បីជាព័ត៌មានមុននឹងចុះស្រាវជ្រាវនៅភូមិបន្ទាប់ក្នុងឃុំដដែល ឬឃុំថ្មី។

ដ្យាក្រាមខាងក្រោមពិពណ៌នាអំពីដំណើរការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោមនៅកម្ពុជា




## ១១. ប្រភពព័ត៌មាន

ប្រសិទ្ធភាពនៃការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោមនៅកម្ពុជា អាស្រ័យលើគុណភាព និងការវិភាគព័ត៌មានដើម្បីសម្រេចថា តើតំបន់ដែលបានរាយការណ៍ជាចម្ការគ្រាប់បែកចង្កោមសង្ស័យ។ ក្រុមស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោមគួរពិនិត្យ និងវិភាគលើទិន្នន័យដែលមានស្រាប់ដូចជា៖ របាយការណ៍បញ្ចប់ការបោសសម្អាត របាយការណ៍កម្ទេចគ្រឿងផ្ទុះ របាយការណ៍ស្រាវជ្រាវមុនៗ របាយការណ៍ជនរងគ្រោះ និងទិន្នន័យទម្លាក់គ្រាប់របស់សហរដ្ឋអាមេរិក។ល។ ដើម្បីយល់ដឹងពីស្ថានភាពតំបន់មានគ្រាប់បែកចង្កោមនៅក្នុងភូមិ ពេលចុះទីវាល ក្រុមស្រាវជ្រាវត្រូវស្វែងរកប្រភពព័ត៌មានដែលមានទំនុកចិត្តខ្ពស់ មិនថាពួកគាត់ជាស្ត្រី បុរស ក្មេងស្រី ក្មេងប្រុស ឬជនមានពិការភាពនោះឡើយ។

តារាងទី១ បង្ហាញពីអ្នកផ្តល់ព័ត៌មានសំខាន់ៗ និងកម្រិតនៃទំនុកចិត្ត

| **អ្នកផ្តល់ព័ត៌មានសំខាន់ៗ** | **ទំនុកចិត្ត** |
|---|---|
| ១. ជនរងគ្រោះដោយសារគ្រាប់បែកចង្កោមនៅក្នុងតំបន់ដែលបានរាយការណ៍ | ខ្ពស់ |
| ២. អ្នកដែលមានមិត្តភ័ក្តិ ឬសមាជិកគ្រួសារ ឬសត្វពាហនៈស្លាប់/ងាប់នៅក្នុងតំបន់ដែលបានរាយការណ៍ | ខ្ពស់ |
| ៣. អ្នកដែលបានឃើញគ្រាប់បែកចង្កោមនៅក្នុងតំបន់ដែលបានរាយការណ៍ | ខ្ពស់ |

| | |
|---|---|
| ៤. អ្នកបានភ្ជួររាស់ដីនៅក្នុងតំបន់ដែលបានរាយការណ៍ | ខ្ពស់ |
| ៥. អ្នកដែលបាន និងកំពុងដាំដុះនៅក្នុងតំបន់ដែលបានរាយការណ៍ | ខ្ពស់ |
| ៦. អ្នករស់នៅក្នុងតំបន់ដែលបានរាយការណ៍ | ខ្ពស់ |
| ៧. អ្នកដែលបាន និងកំពុងចេញ-ចូលក្នុងតំបន់ដែលបានរាយការណ៍ | ខ្ពស់ |
| ៨. ចាស់ព្រឹទ្ធាចារ្យដែលបានឆ្លងកាត់អំឡុងពេលសង្គ្រាម | ខ្ពស់ |
| ៩. អ្នករស់នៅក្បែរ ឬជិតតំបន់ដែលបានរាយការណ៍ | មធ្យម |
| ១០. ម្ចាស់ដីដែលមិនបានចូលរួមក្នុងសកម្មភាពដូចបានរៀបរាប់ខាងលើ | មធ្យម |
| ១១. អ្នករស់នៅជិត (មិនជាប់) តំបន់ដែលបានរាយការណ៍ | ទាប |
| ១២. អ្នករស់នៅក្នុងភូមិ ប៉ុន្តែនៅឆ្ងាយពីតំបន់ដែលបានរាយការណ៍ | ទាប |
| ១៣. អ្នកចំណូលថ្មី ឬអ្នកដែលទើបត្រលប់មករស់នៅក្នុងភូមិ | ទាប |

## ១២. លក្ខខណ្ឌតម្រូវសម្រាប់ក្រុមស្រាវជ្រាវ

សកម្មភាពស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម ត្រូវអនុវត្តដោយបុគ្គលិកដែលមានសមត្ថភាព មានឧបករណ៍សមស្រប និងអនុលោមតាមបទដ្ឋានប្រតិបត្តិការ។ ក្រុមស្រាវជ្រាវត្រូវមានធនធាន ចំណេះដឹង និងជំនាញគ្រប់គ្រាន់ ដើម្បីអនុវត្តសកម្មភាពប្រកបដោយសុវត្ថិភាព ប្រសិទ្ធភាព និងប្រសិទ្ធផល ជាពិសេសត្រូវមានសមត្ថភាពទំនាក់ទំនងជាមួយសហគមន៍ ភាគីពាក់ព័ន្ធ និងអ្នកផ្តល់ព័ត៌មានសំខាន់ៗរួមមាន ស្ត្រី បុរស កុមារី កុមារា និងជនមានពិការភាព។

ក្រុមស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោមគួរមានសមាជិកយ៉ាងតិច ៤នាក់ (ក្រុមចម្រុះភេទ) ក្នុងនោះមានប្រធានក្រុមម្នាក់។ សមាជិកក្រុមទាំងអស់ (រាប់បញ្ចូលទាំងប្រធានក្រុមផង) ត្រូវមានសមត្ថភាព និងទទួលបានការបណ្តុះបណ្តាលពីបច្ចេកទេស ស្តីពីស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម ការស្រាវជ្រាវមិនបច្ចេកទេស វិធីសាស្ត្រ និងជំនាញក្នុងការសម្ភាសន៍ ជំនាញទំនាក់ទំនង និងសង្គ្រោះបឋម។

## ១៣. សុវត្ថិភាព

អាទិភាពទីមួយរបស់ប្រធានក្រុមស្រាវជ្រាវ គឺត្រូវធានាសុវត្ថិភាពសមាជិកក្រុម។ ក្រុមស្រាវជ្រាវមិនត្រូវប៉ះពាល់ ឬចល័តយុទ្ធភណ្ឌគ្រឿងផ្ទុះដាដាច់ខាត។ ប្រសិនបើជួបប្រទះភស្តុតាងគ្រាប់មីនអំឡុងពេលស្រាវជ្រាវ ត្រូវបញ្ឈប់រាល់សកម្មភាពជាបន្ទាន់ ហើយប្រធានក្រុមត្រូវវាយតម្លៃពីស្ថានភាព និងអនុវត្តតាមបទដ្ឋានប្រតិបត្តិការរបស់អង្គភាពខ្លួន។

ពេលក្រុមស្រាវជ្រាវចុះធ្វើការតាមបណ្តោយព្រំដែន ត្រូវសម្របសម្រួលជាមួយអាជ្ញាធរមូលដ្ឋាន និងកងកម្លាំងប្រដាប់អាវុធ ដើម្បីធានាអនុលោមភាពតាមបទបញ្ជាហាមឃាត់នានាក្នុងតំបន់។ ក្រុមស្រាវជ្រាវគួរគិតគូរក្នុងការអញ្ជើញតំណាងអាជ្ញាធរដែនដីពាក់ព័ន្ធអមដំណើរពេលចុះស្រាវជ្រាវ។

## ១៤. នីតិវិធីសង្គ្រោះបន្ទាន់

មុនពេលអនុវត្តការងារ ក្រុមស្រាវជ្រាវត្រូវធ្វើតេស្តមធ្យោបាយទំនាក់ទំនង ត្រូវដឹងពីនីតិវិធីសុវត្ថិភាព និងការជម្លៀសជនរងគ្រោះ ទោះបីជាការជម្លៀសជនរងគ្រោះនោះត្រូវធ្វើតាមផ្លូវគោក ឬផ្លូវអាកាសក៏ដោយ។ ក្រុមស្រាវជ្រាវត្រូវមានសមត្ថភាពក្នុងការជម្លៀសជនរងគ្រោះ។ ក្រុមស្រាវជ្រាវអាចប្រើប្រាស់អ្នកនាំផ្លូវ ឬអ្នកផ្តល់ព័ត៌មានក្នុងការជួយជម្លៀសជនរងគ្រោះ (ដូចជាការលើក ឬសែងជនរងគ្រោះដោយប្រញ៉ាប់ការ)។

មុនពេលចាប់ផ្តើមស្រាវជ្រាវអ្នកនាំផ្លូវ ឬអ្នកផ្តល់ព័ត៌មានចាំបាច់ត្រូវទទួលបានការណែនាំឱ្យដឹងពីតួនាទីរបស់ខ្លួនក្នុងករណីមានគ្រោះថ្នាក់កើតឡើង។

## ១៥. ការចងក្រងឯកសារ

ព័ត៌មានដែលប្រមូលបាន កត់ត្រា និងរាយការណ៍ ដោយក្រុមស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោមមានសារៈសំខាន់ណាស់។ ទោះបីជាគុណភាពព័ត៌មានល្អយ៉ាងណាក៏ដោយ ប្រសិនបើការរាយការណ៍ និងការកត់ត្រាមិនបានត្រឹមត្រូវ វានឹងនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃការស្រាវជ្រាវ។ ដូចនេះ ប្រធានក្រុមត្រូវធានាគុណភាពព័ត៌មានដោយបំពេញទម្រង់របាយការណ៍ស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោមឱ្យបានត្រឹមត្រូវ (ទម្រង់របាយការណ៍ទី១ និងទី២)។

ទម្រង់របាយការណ៍ចំនួនពីរ ដែលត្រូវប្រើប្រាស់សម្រាប់ការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម ៖

- **ទម្រង់របាយការណ៍ទី១** - ព័ត៌មានភូមិ៖ ទម្រង់របាយការណ៍នេះ ប្រើប្រាស់សម្រាប់កត់ត្រាព័ត៌មានភូមិសាស្ត្រនៅក្នុងភូមិ និងកត់ត្រាតំបន់ណាមួយដែលមិនបានស្រាវជ្រាវ ដោយមូលហេតុអ្វីមួយ។
- **ទម្រង់របាយការណ៍ទី២** - ព័ត៌មានចម្ការគ្រាប់បែកចង្កោមសង្ស័យ៖ ទម្រង់របាយការណ៍នេះ ប្រើប្រាស់ដោយក្រុមស្រាវជ្រាវ ដើម្បីកត់ត្រារាល់ព័ត៌មានចម្ការគ្រាប់បែកចង្កោមសង្ស័យនីមួយៗ ដែលនៅក្នុងភូមិ។ ទម្រង់របាយការណ៍មួយនេះ សម្រាប់កត់ត្រាចម្ការគ្រាប់បែកចង្កោមសង្ស័យតែមួយប៉ុណ្ណោះ។

ទម្រង់របាយការណ៍នេះ ត្រូវភ្ជាប់មកជាមួយនូវផែនទីចម្ការគ្រាប់បែកចង្កោមសង្ស័យខ្នាតក្រដាស A4 ដែលបង្ហាញពីស្ថានភាពភូមិសាស្ត្រ (ផ្លូវគោក ផ្លូវទឹក លំនៅដ្ឋាន...។ល។) ទីតាំងជាក់លាក់នៃគ្រាប់បែកចង្កោម និងទីតាំងគ្រោះថ្នាក់។ និមិត្តសញ្ញាដែលត្រូវប្រើប្រាស់លើផែនទីនេះមានក្នុងឧបសម្ព័ន្ធ៥។

ប្រតិបត្តិករដែលអនុវត្តការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម ត្រូវធានាថាទម្រង់របាយការណ៍ស្រាវជ្រាវទី១ និងទី២ ត្រូវបានបំពេញត្រឹមត្រូវ ទាន់ពេលវេលា និងផ្ញើទៅអាជ្ញាធរមីន។

## ១៦. ការធានាគុណភាព (QA) និងការត្រួតពិនិត្យគុណភាព (QC)

ប្រតិបត្តិករដែលអនុវត្តការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម ត្រូវបង្កើតប្រព័ន្ធគ្រប់គ្រងគុណភាពសមស្របមួយ ដើម្បីត្រួតពិនិត្យដំណើរការស្រាវជ្រាវ (QA) និងត្រួតពិនិត្យគុណភាពរបាយការណ៍ស្រាវជ្រាវ (QC)។ ប្រតិបត្តិករដែលអនុវត្តការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម ត្រូវចាត់វិធានការកែតម្រូវចំណុចខ្វះខាតក្នុងការអនុវត្តសកម្មភាពស្រាវជ្រាវ និងចំណុចខ្វះខាតក្នុងការបំពេញរបាយការណ៍ ហើយត្រូវចាត់វិធានការកែតម្រូវនិងទប់ស្កាត់ជាបន្ទាន់។

ប្រតិបត្តិករដែលអនុវត្តការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម គួរប្រៀបធៀបរបាយការណ៍ស្រាវជ្រាវរបស់ខ្លួនជាមួយនឹងរបាយការណ៍បោសសម្អាត ឬកាត់បន្ថយផ្ទៃដី ដើម្បីស្វែងរកចំណុចកែលម្អ។

អាជ្ញាធរមីនត្រូវពិនិត្យដំណើរការស្រាវជ្រាវ (QA) និងត្រួតពិនិត្យគុណភាពរបាយការណ៍ស្រាវជ្រាវ (QC) ហើយត្រូវជូនដំណឹងជាបន្ទាន់ទៅថ្នាក់ដឹកនាំប្រតិបត្តិករ ដែលអនុវត្តការងារស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម នូវកំហុសឆ្គងដែលបានកើតឡើង ឬអាចនឹងកើតឡើង ហើយតាមដានវិធានការកែតម្រូវ និងទប់ស្កាត់របស់ប្រតិបត្តិករ។ ព័ត៌មានលម្អិតស្តីពីការត្រួតពិនិត្យ សូមមើលស្តង់ដាកំចាត់មីនកម្ពុជាលេខ៣។

## ១៧. ភាតព្វកិច្ច

បញ្ហាយុទ្ធភណ្ឌគ្រឿងផ្ទុះ គឺជាបញ្ហាជាតិ ដូចនេះរាជរដ្ឋាភិបាលកម្ពុជាមានទំនួលខុសត្រូវចំពោះជនរងគ្រោះដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះទាំងអស់ក្នុងប្រទេសកម្ពុជា។ អាជ្ញាធរមីននឹងមិនដាក់បន្ទុកការទទួលខុសត្រូវលើប្រតិបត្តិករណាមួយឡើយ ប្រសិនបើប្រតិបត្តិករនោះបានអនុវត្តការស្រាវជ្រាវដោយអនុលោមទៅតាមបទដ្ឋានប្រតិបត្តិការ និងស្តង់ដាកំចាត់មីនកម្ពុជា ហើយស្ថិតក្រោមការត្រួតពិនិត្យគុណភាព (QA&QC) ដោយអាជ្ញាធរមីន។ ករណីមានគ្រោះថ្នាក់ ឬឧប្បត្តិហេតុកើតឡើង ហើយអាជ្ញាធរមីនរកឃើញថាប្រតិបត្តិករនោះពុំបានអនុលោមតាមស្តង់ដា នោះអាជ្ញាធរមីនមានសិទ្ធិពិនិត្យឡើងវិញ និងដកហូតប័ណ្ណទទួលស្គាល់ពីប្រតិបត្តិករនោះក្នុងករណីចាំបាច់។

## ១៨. ការទទួលខុសត្រូវ

ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធសំខាន់ៗក្នុងការអនុវត្តស្តង់ដា៖

### ១៨.១. អាជ្ញាធរមីន

- ត្រូវរៀបចំ ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពស្តង់ដាស្តីពីការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម
- ត្រូវរក្សា និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងព័ត៌មានសម្រាប់ការគ្រប់គ្រង និងរក្សាទុកទិន្នន័យសកម្មភាពមីនជាតិ
- ត្រូវផ្តល់ប័ណ្ណទទួលស្គាល់ដល់ប្រតិបត្តិករ ដែលធ្វើការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម ដោយអនុលោមតាមស្តង់ដាកំចាត់មីនកម្ពុជាលេខ២
- ត្រូវពិនិត្យ និងផ្តល់ការឯកភាពលើបទដ្ឋានប្រតិបត្តិការ ដែលរៀបចំដោយប្រតិបត្តិករអនុវត្តការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម ដើម្បីធានាថាបទដ្ឋាននោះអនុលោមតាមស្តង់ដាកំចាត់មីនកម្ពុជា
- ត្រូវត្រួតពិនិត្យលើដំណើរការស្រាវជ្រាវ (QA) និងគុណភាពរបាយការណ៍ស្រាវជ្រាវ (QC)
- ត្រូវស៊ើបអង្កេតឧប្បត្តិហេតុ និងគ្រោះថ្នាក់ដែលទាក់ទងទៅនឹងការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម និងចាត់វិធានការកែតម្រូវ ឬទប់ស្កាត់ក្នុងករណីចាំបាច់
- គួរផ្តល់ព័ត៌មានដែលមានគុណភាពឱ្យឆ្លើយតបទៅនឹងសំណើរបស់ភាគីពាក់ព័ន្ធ។

១៨.២. ប្រតិបត្តិករអនុវត្តការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម

- ត្រូវរៀបចំ ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពបទដ្ឋានប្រតិបត្តិការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម ដោយអនុលោមទៅតាមស្តង់ដាកំចាត់មីនកម្ពុជា
- ត្រូវមានប័ណ្ណទទួលស្គាល់ និងអាជ្ញាប័ណ្ណពីអាជ្ញាធរមីន ដើម្បីអនុវត្តការស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម
- ត្រូវត្រួតពិនិត្យដំណើរការស្រាវជ្រាវ (QA) និងគុណភាពរបាយការណ៍ស្រាវជ្រាវ (QC) លើក្រុមស្រាវជ្រាវគ្រាប់បែកចង្កោមរបស់ខ្លួន
- ត្រូវធានាថា រាល់ការប្រមូលទិន្នន័យ និងការរាយការណ៍ត្រឹមត្រូវ ទាន់ពេលវេលា ស្របទៅនឹងស្តង់ដាកំចាត់មីនកម្ពុជាលេខ១៧ ស្តីពីការគ្រប់គ្រងព័ត៌មាន
- ត្រូវរាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមីនក្នុងករណីមានគ្រោះថ្នាក់ ឬឧប្បត្តិហេតុ ដែលពាក់ព័ន្ធនឹងការស្រាវជ្រាវ
- គួរផ្តល់យោបល់ឱ្យអាជ្ញាធរមីនដើម្បីកែលម្អស្តង់ដានេះ។

១៨.៣. សមាជិកសហគមន៍រងផលប៉ះពាល់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

- គួរចូលរួមតាមការស្នើសុំរបស់ក្រុមស្រាវជ្រាវមូលដ្ឋានគ្រាប់បែកចង្កោម និងអាជ្ញាធរមីន ដើម្បីផ្តល់ព័ត៌មាន និងចម្លើយត្រឹមត្រូវ
- គួរផ្តល់កិច្ចសហការជាមួយក្រុមស្រាវជ្រាវ និងអាជ្ញាធរមីនឱ្យអស់ពីលទ្ធភាព។

**ឯកសារភ្ជាប់៖**

ឧបសម្ព័ន្ធ១៖ កំណត់ត្រាអំពីការកែលម្អ

ឧបសម្ព័ន្ធ២៖ ស្តង់ដាចាត់ថ្នាក់ប្រភេទដី

ឧបសម្ព័ន្ធ៣៖ ទម្រង់របាយការណ៍ទី១ ព័ត៌មានភូមិ

ឧបសម្ព័ន្ធ៤៖ ទម្រង់របាយការណ៍ទី២ ព័ត៌មានចម្ការគ្រាប់បែកចង្កោមសង្ស័យ

ឧបសម្ព័ន្ធ៥៖ និមិត្តសញ្ញាផែនទី [illegible]

ថ្ងៃ សុក្រ ១៣រោច ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០២៤

**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស**

**អនុប្រធានទី ១ស្តីទី**

អាជ្ញាធរមីន CMAA

**បណ្ឌិត លី ធុជ**

ឧបសម្ព័ន្ធ១

# កំណត់ត្រាអំពីការកែលម្អ

ការគ្រប់គ្រងការកែលម្អស្តង់ដា

ស្តង់ដានីមួយៗចាំបាច់ត្រូវពិនិត្យឡើងវិញជាផ្លូវការរៀងរាល់ ៥ឆ្នាំ ម្តង។ ទោះជាយ៉ាងនេះក្តី ការពិនិត្យ ឬកែសម្រួលឡើងវិញអាចធ្វើឡើងមុនពេលកំណត់ ក្នុងគោលបំណងពង្រឹងសុវត្ថិភាពប្រតិបត្តិការ ប្រសិទ្ធភាព និងប្រសិទ្ធផល ។

